ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour Suprême

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 13-Feb-2019, 14:52
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC

| | |
|---|---|
| នៅចំពោះមុខ: | **ចៅក្រម គង់ ស្រ៊ីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Phillip RAPOZA** |
| | **ចៅក្រម យ៉ា ណារិន** |
| កាលបរិច្ឆេទ: | **ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩** |
| ភាសា: | **ខ្មែរ/អង់គ្លេស** |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

---

# សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្ដីសង្ខេប នៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

**មេធាវីជនជាប់ចោទ**

ស៊ុន អារុន

Victor KOPPE

គង់ សំអុន

Anta GUISSÉ

01600932



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល"បណ្ដឹងសាទុក្ខភ្លាមរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្ដីសង្ខេបសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨" ដែលបណ្ដឹងសាទុក្ខនេះបានដាក់នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ("បណ្ដឹងសាទុក្ខភ្លាមៗ")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសេចក្ដីសង្ខេបនៃសាលក្រម និងការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងការទទួលខុសត្រូវ និងការប្រកាសទោសជនជាប់ចោទក្នុងសំណុំរឿង ០០២/០២ និងបានជូនដំណឹងភាគី សាធារណជនថា សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនៃសាលក្រម នេះ នឹងត្រូវជូនដំណឹងតាមពេលវេលាសមស្រប[2]។ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា "យោងតាមវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ពេលវេលាកំណត់សម្រាប់ការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ប្រសិនបើមាន នឹងត្រូវគិតចាប់ពីថ្ងៃទីមួយ នៃប្រតិទិនបន្ទាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រម ដែលមានសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរជាភាសា ខ្មែរ និងភាសាផ្លូវការដទៃទៀតរបស់ អ.វ.ត.ក ដែលបានជ្រើសរើសដោយភាគីនីមួយៗអនុលោមតាមវិធាន ២.២ នៃសេចក្ដីណែនាំអនុវត្ត"[3]។

2. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ មេធាវីការពារក្ដី ខៀវ សំផន ("មេធាវីការពារក្ដី") បានដាក់បណ្ដឹង សាទុក្ខភ្លាមៗជាភាសាខ្មែរ និងបារាំង ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

---

[1] បណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1 ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

[2] ប្រតិចារឹកសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ឯកសារលេខ E1/529.1 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

[3] អង្គជំនុំជម្រះសាលាដំបូង សេចក្ដីសង្ខេបនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៩។

3. សហព្រះរាជអាជ្ញា បានដាក់សារណាតបរបស់ខ្លួនជាភាសាអង់គ្លេសនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ("សារណាតប")[4] ដោយអនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល[5]។ ការបកប្រែជាភាសាខ្មែរនៃសារណាតបនេះ ត្រូវបានដាក់នៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៨ និងបានជូនដំណឹងនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៨។

4. មេធាវីការពារក្តីបានដាក់ចម្លើយតបនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៩ ("ចម្លើយតប")[6]។

## II. **ភាពអាចទទួលយកបាន**

### ក. សារណា

5. មេធាវីការពារក្តីបានលើកឡើងថា បណ្តឹងសាទុក្ខនេះអាចទទួលយកបានដោយស្របតាមវិធាន ១០៥(១)(ខ) វិធាន ១០៥(២) និង ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ឬយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល[7]។

6. នៅក្នុងទឡ្ហីករណ៍ទីមួយស្តីពីភាពអាចទទួលយកបាន មេធាវីការពារក្តីបានបញ្ជាក់ថា ការប្រកាសសេចក្តីសង្ខេបនៃសាលក្រម និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ គឺជាការប្រកាសនូវ"ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះ"តាមវិធាន ១០១(១)(ខ) នៃវិធានផ្ទៃក្នុង[8] ហើយ *តាមភាពជាក់ស្តែង* គឺជា"សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង" បើផ្អែកលើខ្លឹមសារវិធាន ១០៥(១) នៃវិធានផ្ទៃក្នុង។ ហេតុនេះ មេធាវីការពារក្តីបានអះអាងថា បណ្តឹងសាទុក្ខនេះគប្បីត្រូវបានចាត់ទុកជាបានការ ដោយសារជនជាប់ចោទត្រូវបានផ្តល់សិទ្ធិធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ដោយអនុលោមតាមវិធាន ១០៥(១)(ខ)

---

[4] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមដែលត្រូវបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1/2 ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

[5] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបតែមួយភាសា ឯកសារលេខ E463/1/1/1 ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨។ *សូមមើលផងដែរ* សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ តែមួយភាសា ឯកសារលេខ E463/1/1 ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

[6] ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1/2/1 ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៨។

[7] បណ្តឹងសាទុក្ខ កថាខណ្ឌ ៩។

[8] បណ្តឹងសាទុក្ខ កថាខណ្ឌ ១០ ដល់ ១២។

នៃវិធានផ្ទៃក្នុង[9]។ ទោះជាយ៉ាងណាក្តី នៅក្នុងទឡ្ហីករណ៍ទីពីរស្តីពីភាពអាចទទួលយកបាន មេធាវីការពារក្តីបានយល់ស្របថា ការប្រកាសសេចក្តីសង្ខេបនៃសាលក្រម និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង "*តាមន័យចង្អៀត* ពុំមែនជាការប្រកាសសាលក្រម បើផ្អែកតាមខ្លឹមសារនៃវិធានដែលកំណត់អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅចំពោះមុខ អ.វ.ត.ក ឡើយ"[10]។ ផ្អែកតាមការយល់ឃើញរបស់ខ្លួន ដូចនេះ សេចក្តីសម្រេចដែលបានចេញនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ គប្បីយ៉ាងហោចណាស់ត្រូវបានចាត់ទុកថា"មានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" និងបើកផ្លូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗតាមវិធាន ១០៥(២) និង ១០៤(៤)(ក)[11]។ ជាចុងក្រោយ ប្រសិនបើបណ្តឹងសាទុក្ខនេះ ពុំត្រូវបានចាត់ទុកជាបានការដោយផ្អែកលើទឡ្ហីករណ៍ទាំងពីរដែលបានលើកឡើងនោះទេ មេធាវីការពារក្តីបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលអនុវត្តយុត្តាធិការរបស់ខ្លួន និងសុំឱ្យធ្វើអន្តរាគមន៍ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ ក្នុងករណីដែលគ្មានបទប្បញ្ញត្តិជាក់លាក់ចែងអំពីស្ថានភាពបែបនេះដែលបង្កឡើងដោយអង្គជំនុំជម្រះសាលាដំបូង[12]។

7. សហព្រះរាជអាជ្ញាបានឆ្លើយតបថា បណ្តឹងសាទុក្ខនេះយឺតពេល ដោយសារមេធាវីការពារក្តីពុំបានជំទាស់ទៅនឹងដីកាកំណត់កាលបរិច្ឆេទសវនាការ ដែលបានជូនដំណឹងអំពីការសម្រេចប្រកាសសេចក្តីសង្ខេបនៃសាលក្រម ហើយសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនឹងចេញតាមក្រោយ[13]។ សហព្រះរាជអាជ្ញាបានអះអាងបន្តទៀតថា បណ្តឹងសាទុក្ខនេះពុំអាចទទួលយកបាន នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ដោយផ្អែកលើទឡ្ហីករណ៍ចំនួនបី[14]។

8. ទីមួយ សហព្រះរាជអាជ្ញាបានអះអាងថា បណ្តឹងសាទុក្ខនេះធ្វើឡើងមុនពេលកំណត់[15] ដែលជំទាស់ទៅនឹងការជ្រើសរើសផ្នែកនីតិវិធីរបស់អង្គជំនុំជម្រះក្នុងការប្រកាសសេចក្តីសង្ខេបសាលក្រម និងការយល់

---

[9] បណ្តឹងសាទុក្ខ កថាខណ្ឌ ១៥ ដល់ ២០។

[10] បណ្តឹងសាទុក្ខ កថាខណ្ឌ ២១ ដល់ ២៣។

[11] បណ្តឹងសាទុក្ខ កថាខណ្ឌ ២៤ ដល់ ២៧។

[12] បណ្តឹងសាទុក្ខ កថាខណ្ឌ ២៨ ដល់ ៣៣។

[13] សារណាតប កថាខណ្ឌ ៦ យោងទៅលើដីកាកំណត់កាលបរិច្ឆេទសម្រាប់ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ឯកសារលេខ E462 ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៨។

[14] សារណាតប កថាខណ្ឌ ១ និង ៧។

[15] សារណាតប កថាខណ្ឌ ១១។

01600935



ឃើញរបស់ខ្លួន និងថា តាមវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង ការជំទាស់ទៅនឹងសេចក្ដីសម្រេចផ្នែកនីតិវិធីអាចទទួលយកបានតែក្នុងករណីដែលធ្វើឡើងប្រឆាំងទៅនឹងសាលក្រមចុងក្រោយជាលាយលក្ខណ៍អក្សរលើអង្គសេចក្ដីដែលពុំទាន់បានចេញនៅឡើយ។ ទីពីរ រំលឹកអំពីដែនកំណត់នៃយុត្តាធិការរបស់អង្គជំនុំជម្រះដោយអនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាបានលើកឡើងថា សេចក្ដីសម្រេចផ្នែកនីតិវិធីដើម្បីប្រកាសសេចក្ដីសង្ខេបសាលក្រម និងការយល់ឃើញនៃ សាលក្រមដែលមានសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរដែលនឹងដាក់តាមក្រោយ តាមធម្មតាបានបញ្ចប់ដំណាក់កាលជំនុំជម្រះ ប៉ុន្តែពុំមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ដោយពុំអាចធ្វើបណ្ដឹងសាទុក្ខលើសាលក្រមនោះបានឡើយ[16]។ ទីបី សហព្រះរាជអាជ្ញាអះអាងថា មេធាវីការពារក្ដីពុំបានបង្ហាញថា ការធ្វើអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលដោយផ្អែកលើយុត្តាធិការ (ដែលមានលក្ខណៈបន្ទាប់បន្សំចំពោះបញ្ហានៅចំពោះមុខអង្គជំនុំជម្រះ) ជាការសមហេតុផល ក្នុងករណីដែលការប្រកាសសេចក្ដីសង្ខេបសាលក្រម និងការយល់ឃើញនេះ ត្រូវបានធ្វើឡើងនៅមុនការចេញសាលក្រមមានសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរដោយមានការរំពឹងទុកនូវកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ដែលអង្គជំនុំជម្រះពុំទាន់បានទទួលនៅឡើយ[17]។

9. មេធាវីការពារក្ដីបានបញ្ជាក់ម្ដងទៀតនៅក្នុងចម្លើយតបថា បណ្ដឹងសាទុក្ខនេះអាចទទួលយកបានផ្អែកលើទឡ្ហីករណ៍ទាំងបីដែលបានលើកឡើងនោះ[18]។ ទាក់ទងទៅនឹងពេលវេលាដាក់បណ្ដឹងសាទុក្ខ មេធាវីការពារក្ដីអះអាងថា ខ្លួនពុំអាចជំទាស់ទៅនឹងដីកាកំណត់កាលបរិច្ឆេទសវនាការបាន[19] ដោយសារពុំមានសំណើណាមួយត្រូវបានអនុញ្ញាតឱ្យធ្វើឡើងក្នុងអំឡុងពេលនៃកិច្ចពិភាក្សាសម្រេច[20] ហើយដីកានេះ ពុំត្រូវបានអនុញ្ញាតឱ្យធ្វើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនោះឡើយ[21] ដែលខុសពី"ផ្នែកសម្រេចសេចក្ដី"ដែលអង្គជំនុំជម្រះបានចេញកាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៦[22]។

---

[16] សារណាតប កថាខណ្ឌ ៨ ដល់ ១០។

[17] សារណាតប កថាខណ្ឌ ១២ ដល់ ១៣។

[18] ចម្លើយតប កថាខណ្ឌ ២៣។

[19] ចម្លើយតប កថាខណ្ឌ ១៥ ដល់ ១៧។

[20] ចម្លើយតប កថាខណ្ឌ ១៦ យោងទៅលើវិធាន ៩៦(២) នៃវិធានផ្ទៃក្នុង។

[21] ចម្លើយតប កថាខណ្ឌ ១៧ យោងទៅលើវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

[22] ចម្លើយតប កថាខណ្ឌ ១៨ ដល់ ២៣ យោងទៅលើវិធាន ១០១(១)(ខ) នៃវិធានផ្ទៃក្នុង។

## ខ. ការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូល

### ១. ភាពអាចទទួលយកបានតាមវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង

10. ពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍ទីមួយនៃភាពអាចទទួលយកបាន អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អនុលោមតាមវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង ជនជាប់ចោទអាចដាក់"បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"។ ផ្អែកតាមវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខត្រូវដាក់"ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬការជូនដំណឹងនៃសាលក្រមនេះ ក្នុងករណីសមស្រប"។

11. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការជំទាស់ផ្អែកនីតិវិធីដែលបានលើកឡើងដោយមេធាវីការពារក្ដី ពុំមែនជា"បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"ដូចមានចែងក្នុងវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុងឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសេចក្ដីសង្ខេបនៃសាលក្រមនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ និងបានបញ្ជាក់យ៉ាងច្បាស់ថា "សំអាងហេតុ ដែលមានអានុភាពផ្លូវច្បាប់មានសរសេរនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងមាន [...] នៅក្នុងពេលវេលាសមស្របខាងមុខ"[23]។ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់បន្ថែមទៀតថា "រយៈពេលកំណត់សម្រាប់ការដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខ ប្រសិនបើមាន នឹងត្រូវចាប់ផ្ដើមរាប់មួយថ្ងៃបន្ទាប់នៃថ្ងៃប្រតិទិន ក្រោយពីការបញ្ជូននូវការជូនដំណឹងពីសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ..."[24]។

12. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការជំទាស់ផ្អែកនីតិវិធីពាក់ព័ន្ធទៅនឹងពេលវេលានៃការប្រកាសសេចក្ដីសង្ខេបសាលក្រម និងការយល់ឃើញនៅមុនពេលការចេញសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ បានធ្វើឡើងមុនពេលកំណត់ និងពុំអាចធ្វើទៅបានដោយផ្អែកលើវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង ដែលអនុវត្តទៅលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដី *បើតាមន័យចង្អៀត*។

---

[23] ប្រតិចារឹកសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ឯកសារលេខ E1/529.1 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៣។

[24] ប្រតិចារឹកសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ឯកសារលេខ E1/529.1 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៥៧។

## ២. ភាពអាចទទួលយកបានតាមវិធាន ១០៥(២) និង ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង

13. ចំពោះទម្អឹករណ៍ទីពីរនៃភាពអាចទទួលយកបាន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បណ្ដឹងសាទុក្ខនេះពុំស្ថិតក្នុងវិសាលភាពនៃវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ដែលកម្រិតបណ្ដឹងសាទុក្ខភ្លាមៗត្រឹមបណ្ដឹងណាដែលកើតចេញពី"សេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី"។

14. សិទ្ធិធ្វើបណ្ដឹងសាទុក្ខភ្លាមៗធានាច្បាស់ថា លទ្ធភាពធ្វើបណ្ដឹងសាទុក្ខមានអត្ថិភាព នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបញ្ចប់ដោយពុំបានឈានទៅដល់សាលក្រមស្ថាពរ និងដោយពុំបានផ្ដល់ឱកាសធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនោះ[25] នៅក្នុងពេលដំណាលគ្នាទៅនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដី។ ក្នុងករណីនេះ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការប្រកាសផ្នែកសម្រេចសេចក្ដីនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ តាមធម្មតាបញ្ចប់ដំណាក់កាលជំនុំជម្រះ ប៉ុន្តែពុំមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីស្របតាមខ្លឹមសារនៃវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ឬដកហូតសិទ្ធិរបស់ជនជាប់ចោទក្នុងការពិនិត្យលើអង្គសេចក្ដីនៃការដាក់ពិរុទ្ធភាព និងការប្រកាសទោសឡើយ[26]។ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ច្បាស់លាស់ថា សាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ នឹងចេញក្នុងពេលសមស្រប[27] និងថា ការចេញនេះ គឺជាការកំណត់រយៈពេលពាក់ព័ន្ធសម្រាប់ការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ[28]។

15. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា មេធាវីការពារក្ដីពុំបានបង្ហាញនូវកាលៈទេសៈណាមួយដែលគួរឱ្យជឿបានថា នឹងរារាំងអង្គជំនុំជម្រះក្នុងការចេញសាលក្រមចុងក្រោយជាលាយលក្ខណ៍អក្សរ

---

[25] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឯកសារលេខ E95/8/1/4 ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១២ កថាខណ្ឌ ៩។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ឯកសារលេខ E163/5/1/13 ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ២២។

[26] បណ្ដឹងសាទុក្ខ កថាខណ្ឌ ២៦។

[27] ប្រតិចារឹកសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ឯកសារលេខ E1/529.1 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នា ២០១៨ ទំព័រ ៣។

[28] ប្រតិចារឹកសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ឯកសារលេខ E1/529.1 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នា ២០១៨ ទំព័រ ៥៧។

ដែលមានសំអាងហេតុពេញលេញលើអង្គសេចក្តី ឬមួយទៀត បានដកសិទ្ធិ ខៀវ សំផន ក្នុងការធ្វើបណ្តឹងសាទុក្ខនោះឡើយ។

## ៣. ភាពអាចទទួលយកបានពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ

16. ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះគប្បីប្រើប្រាស់យុត្តាធិការដែលខ្លួនមានក្នុងការសម្រេចលើបញ្ហានេះឡើយ។ មេធាវីការពារក្តីពុំបានបង្ហាញថា ការអន្តរាគមន៍របស់អង្គជំនុំជម្រះ អនុលោមតាមយុត្តាធិការរបស់ខ្លួន ដែលមានលក្ខណៈបន្ទាប់បន្សំទៅលើបញ្ហានៅចំពោះមុខ ជាការសមហេតុផលនៅក្នុងកាលៈទេសៈបច្ចុប្បន្ន។ ដោយហេតុថា សាលក្រមចុងក្រោយជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ និងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខដែលរំពឹងទុកនោះ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយ ទើបអង្គជំនុំជម្រះពុំទាន់បានទទួលបញ្ហានេះមកដោះស្រាយដែលតម្រូវឱ្យប្រើប្រាស់យុត្តាធិការរបស់ខ្លួន។

17. អង្គជំនុំជម្រះរលឹកផងដែរថា យុត្តាធិការនេះ គឺពាក់ព័ន្ធទៅនឹងកាលៈទេសៈចាំបាច់ដែលតម្រូវឱ្យមានការធានានូវកិច្ចការរដ្ឋបាលតុលាការឱ្យបានល្អ និងត្រឹមត្រូវ និងប្រើប្រាស់តែក្នុងករណីជាលក្ខណៈបន្ទាប់បន្សំទៅនឹងយុត្តាធិការចម្បងរបស់ខ្លួនតែប៉ុណ្ណោះ[29]។ ជាពិសេស អង្គបុរេជំនុំជម្រះបានប្រើប្រាស់យុត្តាធិការរបស់ខ្លួនក្នុងការពិនិត្យលើបញ្ហាពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍ក្នុងពេលខាងមុខ ក្នុងករណីដែលសិទ្ធិអនុញ្ញាតឱ្យធ្វើបណ្តឹងឧទ្ធរណ៍ មានអត្ថិភាព និងអាចលែងមានអានុភាពដោយសារការរំលោភបំពានមកលើសិទ្ធិជាក់លាក់ជាមូលដ្ឋាននោះ[30]។ ហានិភ័យបែបនេះពុំមានអត្ថិភាពក្នុងករណីបច្ចុប្បន្ននេះទេ។

18. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា មេធាវីការពារក្តីពុំបានបង្ហាញថា ការប្រកាសសេចក្តីសង្ខេបនៃសាលក្រម និងការយល់ឃើញនៅមុនពេលចេញសាលក្រមចុងក្រោយជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ បានដកហូតសិទ្ធិរបស់ ខៀវ សំផន ក្នុងការធ្វើបណ្តឹងសាទុក្ខ ឬធ្វើឱ្យលែងមានអានុភាពនោះឡើយ។ អង្គជំនុំជម្រះសន្និដ្ឋានបន្ថែមទៀតថា ការលើកឡើងអំពីការរំលោភបំពានលើសិទ្ធិផ្នែកនីតិវិធីរបស់ជនជាប់

---

[29] *សូមមើល ឧ.* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺ ឯកសារលេខ E284/2/1/2 ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ១២។

[30] *សូមមើល ឧ.* សេចក្តីសម្រេចលើសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការបកស្រាយឱ្យបានទូលំទូលាយនូវវិសាលភាពដែលអនុញ្ញាតនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបំភ្លឺនីតិវិធីសម្រាប់ការធ្វើមោឃភាពដីកាដំណោះស្រាយ ឬផ្នែកខ្លះនៃដីកានេះប្រសិនចាំបាច់ ឯកសារលេខ D158/1 ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ១២។

ចោទ[31] គ្រាន់តែជាសម្មតិកម្មសុទ្ធសាធ និងថា ការអន្តរាគមន៍របស់អង្គជំនុំជម្រះពុំមានភាពចាំបាច់នៅក្នុងដំណាក់កាលនេះ ក្នុងការធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះឡើយ។

[31] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៥។

## III. ផ្នែកសម្រេចសេចក្តី

19. យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**សម្រេច** បដិសេធចោលបណ្តឹងសាទុក្ខភ្លាមៗ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**